multicultural communication

ផលិតចងក្រងដោយ NSW HEALTH DEPARTMENT

Khmer
December 2002
[DOH-7105]

# ជំងឺប្រដាំងរមាស់

## Chlamydia

### តើជំងឺប្រដាំងរមាស់ជាអ្វី?

ជំងឺប្រដាំងរមាស់ជារោគឆ្លងតាមរយៈការរួមភេទ ដែលអាចឃាយើទាំងបុរស និងស្ត្រី។ ជំងឺនេះបណ្តាលមកពីពួកបាក់តេរី។ មនុស្សជាច្រើនដែលឆ្លងមេរោគបាក់តេរីនេះពុំមានចេញរោគសញ្ញាទេ ប៉ុន្តែអាចចំលងមេរោគនេះបាន។ ជំងឺប្រដាំងរមាស់អាចប៉ះពាល់បំពង់បង្ហូរទឹកនោម, កស្បូន, បំពង់ផ្ទុកលាមក និង ទ្វារលាមក, បំពង់ក និង ភ្នែក។ ជំងឺប្រដាំងរមាស់អាចផ្តល់ផលវិបាកស្មុគស្មាញ ប៉ុន្តែ គេអាចបង្ការវាបាន។

### តើអ្នកឆ្លងជំងឺប្រដាំងរមាស់ដោយរបៀបណា?

ជំងឺប្រដាំងរមាស់ឆ្លងតាមរយៈការរួមភេទជាមួយមនុស្សដែលមានជំងឺនេះ។

មនុស្សដែលប្រឈមនឹងការឆ្លងជំងឺប្រដាំងរមាស់ខ្លាំងជាងគេ:

- បុរស និងស្ត្រីក្មេងដែលប្រព្រឹត្តការរួមភេទ
- ជនដែលផ្លាស់ប្តូរដៃគូរួមភេទច្រើននាពេលថ្មីៗនេះ
- ជនដែលមានជំងឺកាមរោគណាមួយទៀតនាពេលថ្មីៗនេះ

### តើលោកអ្នកដឹងដោយរបៀបណាថា ខ្លួនមានជំងឺប្រដាំងរមាស់?

ក្រោយពីការឆ្លងមេរោគនេះ រោគសញ្ញានឹងកើតឡើងក្នុងរយៈពេលពី ២ ទៅ ១៤ ថ្ងៃ។ ក៏ប៉ុន្តែ អ្នកខ្លះអាចផ្ទុកមេរោគនេះរាប់ខែ ឬ រាប់ឆ្នាំដោយពុំដឹងខ្លួន។

### ចំពោះស្ត្រី

បើសិនស្ត្រីណាមានជំងឺប្រដាំងរមាស់ គេអាចសំគាល់ឃើញៈ

- ការចុកឬការឈឺចាប់នៅផ្នែកខាងក្រោមពោះ
- ការមករដូវមានការប្រែប្រួល (មានន័យថា មានរដូវមិនទៀតទាត់)
- ការឈឺចាប់នៅពេលបត់ជើងតូច
- ការធ្លាក់ឈាម ឬ ឈឺចាប់ នៅពេល ឬក្រោយពេលរួមភេទ
- ការធ្លាក់សមានការប្រែប្រួល

### ចំពោះបុរស

បើសិនបុរសមានជំងឺប្រដាំងរមាស់ គេអាចសំគាល់ឃើញៈ

- ការចេញខ្ទុះពីលឹង្គ

- ការឈឺចាប់នៅពេលបត់ជើងតូច
- ការហើម ឬឈឺចាប់នៅពងស្វាស

**ចំពោះបុរសនិងស្ត្រី**
ការបង្ករោគនេះនៅទ្វារលាមកអាចកើតមាន ប៉ុន្តែជាទូទៅគេពុំបានចាប់ភ្លឹកឡើយ។ ជួនកាលរោគនេះ អាចបណ្តាលឲ្យមានការឈឺចាប់ ឬ ចេញខ្ទុះនៅទ្វារលាមក។

**តើមានតេស្តរកជំងឺប្រាំងរមាស់ឬទេ?**
គ្រូពេទ្យនៅក្នុងតំបន់ ឬមន្ទីរសុខភាពផ្លូវភេទរបស់លោកអ្នកអាចធ្វើរោគវិនិច្ឆ័យរកជំងឺប្រាំងរមាស់បាន។ គ្រូពេទ្យនឹងផ្តិតយកវត្ថុរាវពីបំពង់បង្ហូរទឹកនោម, កស្បូនឬ ទ្វារលាមក ឬ យកទឹកនោមទៅពិនិត្យ។ គេនឹងធ្វើតេស្តសំណាកវត្ថុរាវ ឬទឹកនោមនេះ ដើម្បីរកជំងឺប្រាំងរមាស់នៅមន្ទីរពិសោធន៍ណាមួយ។

**តើការព្យាបាលជំងឺប្រាំងរមាស់មានអ្វីខ្លះ?**
ជំងឺប្រាំងរមាស់អាចព្យាបាលបានដោយស្រួល ដោយការប្រើថ្នាំអង់ទីប៊ីយ៉ូទីក។ ការទៅជួបវេជ្ជបណ្ឌិត ឬមន្ទីរសុខភាពផ្លូវភេទដើម្បីធ្វើតេស្ត និងព្យាបាលគឺជាការសំខាន់ចាំបាច់ណាស់។ បើសិនរោគសញ្ញាកើតមានឡើងម្តងទៀត សូមត្រឡប់ទៅជួបវេជ្ជបណ្ឌិត ឬមន្ទីរសុខភាពផ្លូវភេទវិញ។

ការព្យាបាលដោយការប្រើថ្នាំអង់ទីប៊ីយ៉ូទិកឲ្យគ្រប់កំរិត គឺជាការសំខាន់ចាំបាច់ណាស់ សំរាប់លោកអ្នក ពីព្រោះមេរោគនៃជំងឺប្រាំងរមាស់ប្រហែលជាពុំទាន់ងាប់ទាំងស្រុងឡើយ ទោះបីជារោគសញ្ញាទាំងឡាយបានបាត់អស់ហើយក៏ដោយ។ ជាការសំខាន់ចាំបាច់ផងដែរ ដែលលោកអ្នកមិនត្រូវរួមភេទ យ៉ាងហោចណាស់ក៏ ៧ ថ្ងៃដែរ ក្រោយពីបានចាប់ផ្តើមការព្យាបាល ដោយសារជំងឺនេះនៅមានលទ្ធភាពឆ្លងនៅឡើយ។

**តើជំងឺនេះមានផ្តល់ផលវិបាកស្មុគស្មាញឬទេ?**
មាន។ បើសិនជំងឺប្រាំងរមាស់មិនបានទទួលការព្យាបាលដោយត្រឹមត្រូវទេ ជំងឺនេះអាចផ្តល់ផលវិបាកស្មុគស្មាញធ្ងន់ធ្ងរ។

**ផលវិបាកស្មុគស្មាញចំពោះស្ត្រីរួមមាន:**
- ជំងឺរលាកអាងត្រគាក (pelvic inflammatory disease)។ ហេតុការណ៍នេះ អាចកើតឡើងកាលណាសរីរាង្គបន្តពូជដែលនៅជិតអាងត្រគាករលាក។
- ការស្អិតជាប់គ្នានៅអាងត្រគាក និងការឈឺចាប់រ៉ាំរ៉ៃនៅអាងត្រគាក
- ភាពមិនអាចមានកូនដោយសារការខូចដៃស្បូន (ដោយសារស្លាកស្នាមជាលិកា)
- កូនក្រៅស្បូន (នៅពេលគភ៌ស្ថិតនៅក្នុងដៃស្បូន ជាជាងនៅក្នុងស្បូន)

**ផលវិបាកស្មុគស្មាញចំពោះបុរសរួមមាន:**
- រលាកបំពង់បង្ហូរទឹកនោមម្តងហើយម្តងទៀត (recurrent urethritis)
- រលាកបំពង់បង្ហូរទឹកកាម (epididymitis) ដែលពាក់ព័ន្ធទៅនឹងបំពង់ភ្ជាប់ពងស្វាស

ផលវិបាកស្មុគស្មាញចំពោះស្ត្រី និង បុរសរួមមាន:

- ជំងឺរលាកសន្លាក់ (arthritis)
- ជំងឺឈឺភ្នែក (conjunctivitis and uveitis រលាកភ្នែក) ។
- ជំងឺរលាកបំពង់ផ្លូវលាមក (proctitis)

## តើដៃគូរួមភេទត្រូវការការព្យាបាលឬទេ?

ត្រូវការ។ បើសិនលោកអ្នកមានជំងឺប្រមេះទឹកបាយ លោកអ្នកគប្បីប្រាប់ដៃគូរួមភេទទាំងអស់របស់ខ្លួន ក្នុងរយៈពេល ៦ ខែកន្លងមកនេះ ឲ្យទៅជួបវេជ្ជបណ្ឌិត ឬមន្ទីរសុខភាពផ្លូវភេទដើម្បីធ្វើតេស្ត និងព្យាបាល។

## តើគេអាចបង្ការជំងឺប្រមេះទឹកបាយដោយរបៀបណា?

ការប្រើស្រោមអនាម័យនៅពេលរួមភេទតាមទ្វារមាស ឬទ្វារលាមកអាចបង្ការជំងឺប្រមេះទឹកបាយ និង ជំងឺកាមរោគដទៃទៀត។ ការប្រើស្រោមអនាម័យមានសារសំខាន់ជាពិសេស ចំពោះមនុស្សណាដែលមានដៃគូរួមភេទលើសពីម្នាក់។

## ព័ត៌មានបន្ថែម- **Public Health Units in NSW**

ចំពោះព័ត៌មានបន្ថែម សូមពិគ្រោះយោបល់ជាមួយវេជ្ជបណ្ឌិត ទាក់ទងមន្ទីរសុខភាពផ្លូវភេទតាមតំបន់របស់លោកអ្នក ដែលលោកអ្នកអាចរកឃើញនៅទំព័រអក្សរ “S” នៅផ្នែកបញ្ជីអាជីវកម្ម នៃសៀវភៅ White Pages ឬនៅមន្ទីរសុខភាពសាធារណៈ ឬមណ្ឌលសុខភាពសហគមន៍របស់លោកអ្នក- សូមមើលនៅត្រង់កន្លែង ‘NSW Government’ នៅផ្នែកខាងមុខនៃសៀវភៅ White Pages ។

**Metropolitan Areas**

| | |
|---|---|
| Central Sydney | 9515 3180 |
| South Eastern Sydney | 9382 8333 |
| Northern Sydney | 9477 9400 |
| South Western Sydney | 9828 5944 |
| Western Sydney | 9840 3603 |
| Wentworth | 4734 2022 |

**Rural Areas**

| | |
|---|---|
| Central Coast | 4349 4845 |
| Mid North Coast | 6588 2750 |
| Mid Western | 6339 5548 |
| Hunter | 4924 6477 |
| Illawarra | 4255 2200 |
| New England | 6766 2288 |
| Northern Rivers | 6620 7500 |
| Macquarie | 6841 2216 |
| Southern | 4827 3428 |
| Greater Murray | 6021 4799 |
| Far West | (08) 8080 1499 |

**NSW Department of Health**
73 Miller Street
North Sydney NSW 2059
Tel. (02) 9391 9000
Fax. (02) 9391 9101
TTY. (02) 9391 9900

NSW Health website
www.health.nsw.gov.au